# សុន្ទរកថា

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ថ្លែងក្នុងជំនួបកំពូលរបស់ថ្នាក់ដឹកនាំអាស៊ាន, មូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោក

## ក្រោមប្រធានបទ: ការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និង ការកាត់បន្ថយគម្លាតអភិវឌ្ឍន៍ តាមរយៈសកម្មភាពសហប្រតិបត្តិការតំបន់ និង សកល

## បាលី, ឥណ្ឌូណេស៊ី, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៨

- ***ឯកឧត្តមសហប្រធាន;***
- ***ព្រះចៅស៊ុលតង់, ឯកឧត្តម, លោកជំទាវ, ថ្នាក់ដឹកនាំនៃបណ្តាប្រទេសអាស៊ាន;***
- ***ឯកឧត្តម អាន់តូនីញ៉ូ ហ្គូតេរ៉េស, អគ្គលេខាធិការអង្គការសហប្រជាជាតិ;***
- ***ឯកឧត្តម ប្រធានធនាគារពិភពលោក;***
- ***លោកជំទាវនាយកគ្រប់គ្រងមូលនិធិរូបិយវត្ថុអន្តរជាតិ;***
- ***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !***

ខ្ញុំពិតជាមានសេចក្តីរីករាយ ដោយបានមកចូលរួមក្នុងកិច្ចពិភាក្សាលើប្រធានបទ **«ការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និង ការកាត់បន្ថយគម្លាតអភិវឌ្ឍន៍»** ដែលមានសារៈសំខាន់ចំពោះអនាគតរបស់យើងទាំងអស់គ្នា ជាពិសេស សម្រាប់សហគមន៍អាស៊ាន ។

ជាការពិត, អាស៊ាន គឺជាប្លុកតំបន់មួយដែលមានការរីកចម្រើនឆាប់រហ័ស ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម ដែលជាសេដ្ឋកិច្ចធំបំផុតទី ៦ លើពិភពលោក ជាមួយនឹងប្រជាជនប្រមាណ ៦៤០ លាននាក់ និង ជាកម្លាំងរុញច្រានសំខាន់មួយ សម្រាប់ពាណិជ្ជកម្ម និង កំណើនពិភពលោក ។ ទស្សនវិស័យអនាគតសម្រាប់ អាស៊ាន មានភាពល្អប្រសើរ ដោយយើងបានកំណត់ថា នឹងសម្រេចឱ្យបានកំណើនលើស ៥% ក្នុងឆ្នាំនេះ និង លើសពី ៥% នៅឆ្នាំក្រោយ និង ក្នុងរយៈពេលមធ្យមខាងមុខ ។ ជាការពិត, នៅក្នុងនេះ ក៏មានប្រទេសមួយចំនួន សម្រេចបាននូវកំណើនខ្ពស់លើសកម្រិតមធ្យមផងដែរ រួមបញ្ចូលនូវកម្ពុជាដែលកំពុងមានកំណើនលើសពី ៧% ក្នុងមួយឆ្នាំ ។

ទន្ទឹមគ្នានេះ, អាស៊ានក៏សម្រេចបាននូវវឌ្ឍនភាពល្អប្រសើរក្នុងផ្នែកសង្គម ជាពិសេស លើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និង ការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាភាពប្រសើរឡើងលើសូចនាករសំខាន់ៗនៃការអភិវឌ្ឍមនុស្ស ។ លើសពីនេះ, អាស៊ាន គឺជាតំបន់ដែលធ្វើមូលដ្ឋានីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព មុនគេផងដែរ ។ អាស៊ានប្រកាន់ខ្ជាប់នូវគោលការណ៍នៃភាពជាម្ចាស់, ការទទួលខុសត្រូវ, និង កិច្ចសហប្រតិបត្តិការ, ដែលផ្តល់សារៈសំខាន់ចំពោះការតភ្ជាប់សេដ្ឋកិច្ច, ការផ្សារភ្ជាប់សង្គម, ស្ថិរភាព, និង សាមគ្គីភាព, នៅក្នុងប្រព័ន្ធអេកូឡូស៊ីមួយដែលបើកចំហរ និង អំណោយផលចំពោះគ្រប់សកម្មភាពសេដ្ឋកិច្ច, ពាណិជ្ជកម្ម, ការវិនិយោគ, និង ការបង្កើតគំនិតផ្តួចផ្តើមថ្មីៗ ។

***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***

បច្ចុប្បន្ន, សកលលោកកំពុងវិវត្តន៍ទៅរកក្របខណ្ឌពហុប៉ូលថ្មី, ការប្រែប្រួលកម្លាំង និង តុល្យការនៃអំណាចសកល ព្រមទាំងកំពុងប្រឈមនឹងបញ្ហានានាពាក់ព័ន្ធនឹងភូមិសាស្ត្រនយោបាយ, ភេរវកម្ម និង អំពើហិង្សា ក្នុងតំបន់ និង សកលលោក ក៏ដូចជាការប្រែប្រួលអាកាសធាតុ និង ភាពមិនប្រាកដប្រជាក្នុងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពិភពលោក ដោយសារតែគោលនយោបាយគាំពារនិយម, សង្គ្រាមពាណិជ្ជកម្ម, ការរំលោភលើប្រព័ន្ធពហុភាគីនិយម និង ភាព-ងាយរងគ្រោះក្នុងវិស័យហិរញ្ញវត្ថុសកល និង តំបន់ ។ ជាងនេះទៀត, អាស៊ានក៏ប្រឈមនឹងបញ្ហាជាក់ស្តែងរបស់ខ្លួនមួយចំនួនផងដែរ ជាអាទិ៍ កំណើននៃភាពចាស់ជរា និង ការថយចុះកម្លាំងពលកម្ម, គម្លាតជំនាញក្នុងសម័យបដិវត្តឧស្សាហកម្មទី ៤.០, គម្លាតអភិវឌ្ឍន៍រវាងប្រទេសសមាជិក និង ការបែងចែកផ្លែផ្កាកំណើនប្រកបដោយសមធម៌ ព្រមទាំងបញ្ហានិរន្តរភាពនៃការប្រើប្រាស់ធនធានធម្មជាតិ ។

ក្នុងបរិការណ៍នេះ, អាស៊ានត្រូវពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀត ជាមួយដៃគូដែលមានស្រាប់, ស្តារឡើងវិញ នូវប្រព័ន្ធពាណិជ្ជកម្មសកលដោយផ្អែកលើមូលដ្ឋានច្បាប់អន្តរជាតិ និង បន្តធ្វើសមាហរណកម្មលើការតភ្ជាប់លើគ្របវិស័យ ដើម្បីពង្រឹងភាពធន់របស់អាស៊ានទៅនឹងការវិវត្តស្ថានភាពនយោបាយ, សេដ្ឋកិច្ច, និង សង្គម ។ ដូច្នេះ, យើងត្រូវធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, គាំពារកំណើនប្រកបដោយបរិយាប័ន្ន, លើកកម្ពស់ឧត្តមភាពប្រកួតប្រជែង និង នវានុវត្តន៍, ជាពិសេស ពង្រឹងការត្រៀមខ្លួនឱ្យប្រសើរជាងមុន តាមរយៈការពង្រឹងយន្តការតំបន់, ការបង្កើនការសម្របសម្រួល និង ការចែករំលែកពត៌មាន ក៏ដូចជាការតាមដានជាប្រចាំនូវស្ថានភាពសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីទប់ស្កាត់ភាពមិនប្រក្រតី និង ដោះស្រាយស្ថានភាពតានតឹងណាមួយដែលអាចកើតឡើង ដូចគ្នានឹងវិបត្តិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុឆ្នាំ ១៩៩៧ និង ឆ្នាំ ២០០៨ ក្នុងគោលដៅធានាសុខមាលភាព និង វឌ្ឍនភាពសង្គម ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ ២០៣០ ។

***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***

ជាងពីរទសវត្សរ៍មកនេះ, កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ ជាមធ្យម ៧.៧% ក្នុងមួយឆ្នាំ ជាមួយនឹងការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដ៏រឹងមាំ ។ ជាពិសេស, កម្ពុជាត្រូវបានទទួលស្គាល់ថា ស្ថិតនៅក្នុងចំណោមប្រទេសឯតទគ្គៈនៃកំណើនលើពិភពលោក ។ កំណើនសេដ្ឋកិច្ចខ្ពស់នេះ បានធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប កាលពីពេលថ្មីៗកន្លងទៅ ហើយមូលដ្ឋានកំណើនកាន់តែមានពិពិធកម្មច្រើនឡើង, ភាពក្រីក្រត្រូវបានកាត់បន្ថយមកនៅត្រឹមក្រោម ១០% និង គម្លាតចំណូលក្នុងចំណោមប្រជាជន ត្រូវបានរក្សាក្នុងកម្រិតទាប តាមរយៈការបែងចែកផលនៃកំណើនដល់គ្រប់ស្រទាប់ប្រជាជន ។ ជាងនេះទៀត, កម្ពុជាក៏សម្រេចបានមុនកាលកំណត់ នូវគោលដៅនៃសូចនាករផ្នែកសង្គមសំខាន់ៗ ទាំងក្នុងវិស័យអប់រំ និង សុខាភិបាល ។ ផ្អែកលើសមិទ្ធផលដែលសម្រេចបានកន្លងមក, រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី ៦ បានដាក់ចេញនូវកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ សំដៅឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជនជាម្ចាស់ឆ្នោតផង ក៏ដូចជាដើម្បីកសាងមូលដ្ឋានគ្រឹះបន្ថែម សម្រាប់ធានានាំកម្ពុជាឈានឆ្ពោះទៅសម្រេចឱ្យបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ ខាងមុខ ។ ក្នុងគោលដៅគោលដៅនេះ, កម្ពុជា បាន និង កំពុង យកចិត្តទុកដាក់បង្កើតឱកាសការងារសម្រាប់យុវជន; លើកកម្ពស់ការទទួលបានសេវាសាធារណៈសំខាន់ៗប្រកបដោយគុណ-

ភាព រួមទាំង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, សេវាអប់រំ, សេវាសុខាភិបាល, និង សេវាមូលដ្ឋានចាំបាច់ផ្សេងទៀត; ធានាសន្តិសុខប្រាក់ចំណូល ជាពិសេស ធានាតុល្យភាព និង កាត់បន្ថយគម្លាតរវាងទីក្រុង និង ជនបទ; បន្តខិតខំពង្រឹង និង ពង្រីកការតភ្ជាប់, ទាំងផ្នែកទន់ និង រឹង; ព្រមទាំងពន្លឿនសមាហរណកម្មសេដ្ឋកិច្ច ទៅក្នុងតំបន់ និង សកលលោក ។

នៅក្នុងបរិការណ៍នេះ, រាជរដ្ឋាភិបាលកម្ពុជាផ្តោតអាទិភាពខ្ពស់ទៅលើ ÷

**១- ការកែទម្រង់ដើម្បីជំរុញកំណើនប្រកបដោយបរិយាប័ន្ន** : **ទី១-** តាមរយៈការពន្លឿនការកែទម្រង់រចនាសម្ព័ន្ធចាំបាច់នានា ដើម្បីបង្កើនភាពប្រកួតប្រជែង និង ជំរុញការធ្វើពិពិធកម្ម រួមមាន ការកាត់បន្ថយចំណាយថាមពល; ការលើកកម្ពស់ការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូន; និង ការដោះស្រាយគម្លាតជំនាញ តាមរយៈការកែលម្អគុណភាពអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ដោយការបង្កើនការវិនិយោគលើយុវជន ដើម្បីចាប់យកឱកាសពីឧត្តមភាពប្រជាសាស្ត្រ និង រក្សាបានកម្លាំងពលកម្មធៀបនឹងប្រជាជនទូទៅ ក្នុងកម្រិត ៦៧% ដល់ឆ្នាំ ២០៣០; និង **ទី២-** តាមរយៈការកែតម្រូវគោលនយោបាយសារពើពន្ធ ដើម្បីគាំទ្របរិយាប័ន្នឱ្យកាន់តែប្រសើរ ដោយផ្លាស់ប្តូរទៅរកប្រភពអ្នកមានចំណូលកាន់តែខ្ពស់ ស្របគ្នានឹងរក្សាបាននូវលម្ហថវិកាដើម្បីបង្កើនចំណាយលើវិស័យហេដ្ឋារចនាសម្ព័ន្ធ, វិស័យសុខភាព, និង ការអប់រំ ។

**២- ការជំរុញការអភិវឌ្ឍឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព** : ដោយផ្តោតលើការពង្រីកកាលានុវត្តភាពសេដ្ឋកិច្ច និង ជំរុញការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និង សង្គម ជាពិសេសនៅតាមទីជនបទ; ការកែលំអលទ្ធផលសុខភាព និង ការអប់រំ និង ការបង្កើនផលិតភាពខ្ពស់ក្នុងវិស័យកសិកម្ម ។ ទន្ទឹមនេះ, ដើម្បីចាប់យកសក្តានុពលពីការកើនឡើងនៃការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ, យើងកំពុងតែគិតគូរ និង រៀបចំហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុបន្ថែម ព្រមទាំងបង្កើនអក្ខរភាពផ្នែកហិរញ្ញវត្ថុ ដែលនឹងជួយពង្រឹងបរិយាប័ន្នហិរញ្ញវត្ថុ ។ កម្ពុជាបាន និង កំពុងធ្វើមូលដ្ឋានីយកម្មពេញលេញនូវគោលដៅអភិវឌ្ឍន៍សកលមកជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃកម្ពុជា ដែលគ្រោងនឹងអនុមតិ នៅដំណាច់ឆ្នាំ ២០១៨ នេះ ។

**៣- ការកែលម្អថែមទៀតនូវបរិយាកាសធុរកិច្ច** : តាមរយៈការអនុវត្តវិធានការមុតស្រួច សំដៅសម្រួលពាណិជ្ជកម្ម, កាត់បន្ថយថ្លៃដើមនៃការធ្វើធុរកិច្ច, សម្រួលការបង្កើត និង ធ្វើធុរកិច្ច ព្រមទាំងបង្កើនការវិនិយោគ និង ឥណទានលើការអភិវឌ្ឍន៍ និង ស្រាវជ្រាវ ដើម្បីគាំទ្រដល់ការបង្កើតការងារ និង ជំរុញកំណើនអាជីវកម្មធុនតូច និង មធ្យម ក្នុងស្រុក ។

***សូមអរគុណ !***